# សំណួរដែលសួរញឹកញាប់ជាងគេ អំពីការពិគ្រោះយោបល់ជាមុន សម្រាប់គម្រោងវារីអគ្គិសនីសាណាខាំ

## ១. អ្វីទៅជាដំណើរការ ការពិគ្រោះយោបល់ជាមុនរបស់គណៈកម្មការទន្លេមេគង្គ (Mekong River Commission – MRC)?

ការពិគ្រោះយោបល់ជាមុន គឺជាដំណើរការមួយក្នុងចំណោមដំណើរការទាំងបី នៃនីតិវិធីស្តីពីការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀង (ហៅកាត់ថា PNPCA)។ ដំណើរការនេះ គឺសំដៅឱ្យប្រទេសជាសមាជិក MRC ធ្វើការពិភាក្សា និងវាយតម្លៃអត្ថប្រយោជន៍ និងហានិភ័យពាក់ព័ន្ធនឹងសំណើគម្រោងប្រើប្រាស់ទឹកណាមួយ ដែលអាចបង្កផលប៉ះពាល់ជាដុំកំភួនលើរបបលំហូរទឹក គុណភាពទឹក និងស្ថានភាពបរិស្ថាន និងសង្គម-សេដ្ឋកិច្ចផ្សេងទៀត តាមដងទន្លេមេគង្គ។

ប្រទេសជាសមាជិកទាំងឡាយ (ប្រទេសជូនដំណឹង) ដែលមានគោលបំណងអនុវត្តគម្រោង ចាំបាច់ត្រូវជូនដំណឹងដល់ប្រទេសផ្សេងទៀត (ប្រទេសទទួលការជូនដំណឹង) និងត្រូវផ្តល់ឱ្យប្រទេសទាំងនោះនូវទិន្នន័យ និងព័ត៌មានដែលខ្លួនមាន។ ដំណើរការនេះ ផ្តល់លទ្ធភាពឱ្យប្រទេសដែលទទួលការជូនដំណឹង ធ្វើការវាយតម្លៃពីផលប៉ះពាល់ដែលអាចកើតមានលើដែនដីរបស់ពួកគេ និងផ្តល់យោបល់លើសំណើគម្រោងប្រើប្រាស់ទឹក។

ដំណើរការនេះ មានគោលបំណងធ្វើឱ្យគណៈកម្មាធិការចម្រុះ (Joint Committee - JC) ពិភាក្សាឈានទៅដល់ការព្រមព្រៀងមួយ អំពីវិធានក្នុងការប្រើប្រាស់ទឹកឱ្យបានល្អបំផុត និងបង្ការការខ្ជះខ្ជាយទឹក និងដាក់ចេញនូវសេចក្តីសម្រេចដោយរួមបញ្ចូលនូវរាល់លក្ខខណ្ឌ ដែលបានឯកភាពគ្នាសម្រាប់គម្រោងនេះ។ គណៈកម្មាធិការចម្រុះ គឺជាស្ថាប័ន ដែលមានសមាសភាគជាតំណាងមកពីប្រទេសសមាជិកទាំងបួននៅកម្រិតប្រធាននាយកដ្ឋាន សម្រាប់រៀបចំការពិគ្រោះយោបល់ជាមុន។

ការពិគ្រោះយោបល់ជាមុននេះ មិនមែនអនុវត្តក្នុងន័យផ្តល់ការអនុម័តដល់សំណើប្រើប្រាស់ទឹកនោះទេ ផ្ទុយទៅវិញ ដំណើរការនេះត្រូវបានរៀបចំឡើង ដើម្បីឱ្យប្រទេសទទួលបានការជូនដំណឹង ផ្តល់ជាអនុសាសន៍ និងដើម្បីឱ្យប្រទេសដែលលើកស្នើគម្រោង ទទួលយកវិធានការមួយចំនួន ដើម្បីបញ្ចៀស កាត់បន្ថយជាអប្បបរមា និងសម្រាលផលប៉ះពាល់អវិជ្ជមានឆ្លងដែនដែលអាចកើតមាន និងរិះរកវិធីល្អប្រសើរដើម្បីចែករំលែកអត្ថប្រយោជន៍នេះ។

បើតាមនីតិវិធី PNPCA ការពិគ្រោះយោបល់ជាមុន មិនមែនជាសិទ្ធិប្រឆាំងនឹងប្រើប្រាស់ទឹក ឬជាសិទ្ធិឯកតោភាគីក្នុងការប្រើប្រាស់ទឹក របស់ប្រទេសជាសមាជិកណាមួយ ដោយពុំបានធ្វើការពិចារណាពីសិទ្ធិ និងការព្រួយបារម្ភប្រទេសផ្សេងទៀតនោះឡើយ។

## ២. តើប្រទេសដែលទទួលបានការជូនដំណឹង មានសិទ្ធិវេតូ ប្រឆាំងនឹងគម្រោងនេះដែរឬទេ?

ទេ។

កិច្ចព្រមព្រៀងទន្លេមេគង្គឆ្នាំ ១៩៩៥ ចែងយ៉ាងច្បាស់ថា ដំណើការការពិគ្រោះយោបល់ជាមុននេះ មិនមែនមានន័យថា ប្រទេសណាមួយមានសិទ្ធិវេតូប្រឆាំងគម្រោងណាមួយ ឬជាសិទ្ធិរបស់ប្រទេសណាមួយ ក្នុងការប្រើប្រាស់ទឹកក្នុងទន្លេនេះដូចដែលបានស្នើ ដោយពុំបានធ្វើការពិចារណាអំពីសិទ្ធិ និងការព្រួយបារម្ភរបស់ប្រទេសផ្សេងទៀត ដែលស្ថិតនៅក្នុងតំបន់ដងទន្លេនោះឡើយ។

## ៣. តើការពិគ្រោះយោបល់ជាមុននេះ ជាដំណើរការផ្តល់ការឯកភាព ដែលចាំបាច់សម្រាប់សំណើគម្រោងណាមួយដែរឬទេ?

ទេ។

ការពិគ្រោះយោបល់ជាមុន មិនមែនជាដំណើរការដើម្បីស្នើសុំការឯកភាពពីប្រទេសជាសមាជិកណាមួយ សម្រាប់គម្រោងនោះទេ។ ផ្ទុយទៅវិញ វាផ្តល់ឱកាសឱ្យប្រទេសដែលទទួលបានការជូនដំណឹង ធ្វើការពិនិត្យគម្រោងឡើងវិញ និងលើកឡើងពីការព្រួយបារម្ភសមស្របរបស់ពួកគេ អំពីផលប៉ះពាល់អវិជ្ជមានឆ្លងដែនលើបរិស្ថាន និងប្រជាជនក្នុងប្រទេសរបស់ពួកគេ ប្រសិនបើមាន។ ដំណើរការនេះ ជួយឱ្យប្រទេសដែលលើកស្នើគម្រោង ស្វែងយល់ឱ្យកាន់តែច្បាស់អំពីការព្រួយបារម្ភទាំងនេះ និងដាក់ចេញនូវវិធានការឆ្លើយតបចាំបាច់។

ឧទាហរណ៍មួយនៃកិច្ចខិតខំប្រឹងប្រែង ដើម្បីឆ្លើយតបទៅនឹងការព្រួយបារម្ភ ដែលប្រទេសជាសមាជិកផ្សេងទៀតបានលើកឡើង ក្នុងអំឡុងដំណើរការការពិគ្រោះយោបល់ជាមុនសម្រាប់គម្រោងទំនប់វារីអគ្គិសនីសាយ៉ាបូរី រដ្ឋាភិបាលឡាវ បានប្តេជ្ញាធ្វើការកែលម្អ និងកែសម្រួលការរៀបចំគម្រោងនេះ ដើម្បីបញ្ចៀស កាត់បន្ថយជាអប្បបរមា និងសម្រាលផលប៉ះពាល់ដែលអាចកើតមាន។ រដ្ឋាភិបាលឡាវ និងក្រុមហ៊ុនអភិវឌ្ឍន៍គម្រោង បានវិនិយោគជាមួយនឹងទឹកប្រាក់យ៉ាងច្រើន ដើម្បីកែសម្រួលការរៀបចំគម្រោងនេះ ជាការឆ្លើយតបទៅនឹងបញ្ហាពាក់ព័ន្ធនឹងបម្លាស់ទីត្រី និងដីល្បាប់ ដែលជាការព្រួយបារម្ភធំៗចំនួនពីរ ដែលបានលើកឡើងក្នុងការពិគ្រោះយោបល់ជាមុន។

## ៤. តើកិច្ចព្រមព្រៀងមេគង្គឆ្នាំ ១៩៩៥ បញ្ជាក់ពីប្រភេទគម្រោង ដែលគួរឆ្លងកាត់ដំណើរការនេះដែរឬទេ?

កិច្ចព្រមព្រៀងបញ្ជាក់។

កិច្ចព្រមព្រៀងទន្លេមេគង្គឆ្នាំ១៩៩៥ និងនីតិវិធីស្តីពីការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀង បញ្ជាក់ពីប្រភេទគម្រោងតាមទីតាំងភូមិសាស្ត្រ និងរបៀបប្រើប្រាស់ធនធានទឹកនៅក្នុងអាងទន្លេមេគង្គក្រោមទៅតាមរដូវកាលក្នុងមួយឆ្នាំ។

គម្រោងដែលដំណើរការដោយផ្ទាល់លើទន្លេ ដែលមានទីតាំងក្នុងដងទន្លេមេគង្គមេ ត្រូវឆ្លងកាត់ដំណើរការ PNPCA។ លើសពីនេះ កិច្ចព្រមព្រៀងទន្លេមេគង្គ និងនីតិវិធី PNPCA អំពាវនាវឱ្យមានការពិគ្រោះយោបល់ជាមុន ប្រសិនបើគម្រោងទាំងនេះ ត្រូវបានចាត់ទុកថាជាគម្រោងដែលមានផលប៉ះពាល់ឆ្លងដែនគួរឱ្យកត់សម្គាល់ លើរបបលំហូរទឹក និងគុណភាពទឹកនៅក្នុងដងទន្លេមេ។

បន្ថែមពីនេះ គម្រោងប្រើប្រាស់ទឹក ឬបង្វែរទឹកបីប្រភេទ ដែលត្រូវឆ្លងកាត់ដំណើរការការពិគ្រោះយោបល់ជាមុន រួមមាន៖

(១) គម្រោងតាមដងទន្លេមេ ដែលប្រើប្រាស់ទឹកក្នុងតំបន់អាងទន្លេមេគង្គនៅរដូវប្រាំង

(២) គម្រោងដែលបង្វែរលំហូរទឹកពីដងទន្លេមេគង្គមេ ទៅតំបន់អាងទន្លេ ផ្សេងទៀតនៅរដូវវស្សា និង

(៣) គម្រោងដែលបង្វែរបរិមាណទឹកដែលនៅសេសសល់ ទៅកាន់ទន្លេផ្សេងទៀត ក្នុងតំបន់អាងទន្លេនៅរដូវប្រាំង។




## ៥. តើដំណើរការការពិគ្រោះយោបល់ជាមុន ត្រូវការពេលប៉ុន្មាន?

ជាធម្មតា ដំណើរការនេះត្រូវការរយៈពេលប្រាំមួយខែ។ ប្រសិនបើគណៈកម្មាធិការចម្រុះ ត្រូវការពេលបន្ថែមទៀត សម្រាប់ធ្វើការពិភាក្សាគ្នា ដំណើរការនេះ អាចនឹងពន្យាពេលបន្ថែមទៀត។

## ៦. តើនឹងមានអ្វីកើតមានឡើង ក្នុងអំឡុងដំណើរការការពិគ្រោះយោបល់ជាមុននេះ?

បន្ទាប់ពីទទួលបានការជូនដំណឹង រួមទាំងឯកសារសម្រាប់គម្រោង ក្រុមការងារនៃគណៈកម្មាធិការចម្រុះរបស់ MRC ជួបប្រជុំ ដើម្បីសម្រេចលើកាលបរិច្ឆេទចាប់ផ្តើមសម្រាប់ដំណើរការការពិគ្រោះយោបល់ជាមុន។ ក្រុមការងារនេះ រួមមានសមាសភាគជាតំណាងបច្ចេកទេសជាន់ខ្ពស់មកពីប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម និងដើរតួនាទីជាស្ថាប័នប្រឹក្សាបច្ចេកទេសសម្រាប់គណៈកម្មាធិការចម្រុះរបស់ MRC ក្នុងការអនុវត្តដំណើរការ PNPCA។

ក្នុងអំឡុងពេលប្រាំមួយខែនេះ គណៈកម្មាធិការចម្រុះ ពិនិត្យលើបញ្ហាបច្ចេកទេសគម្រោង ដើម្បីកំណត់ពីភាពអនុលោមទៅតាមនីតិវិធីស្តីពីរបបលំហូរ និងគុណភាពទឹករបស់ MRC ធ្វើការវាយតម្លៃផលប៉ះពាល់ដែលអាចកើតមានលើបរិស្ថាន និងជីវភាពរស់នៅ និងលើកស្នើនូវវិធានការឆ្លើយតបទៅនឹងការព្រួយបារម្ភទាំងនេះ មុនពេលបញ្ចប់ដំណើរការនេះ។

ការពិនិត្យឡើងវិញ នឹងធ្វើការកំណត់ពីភាពអនុលោមទៅតាមសេចក្តីណែនាំបឋម ស្តីពីការសាងសង់គម្រោងតាមដងទន្លេមេ ក្នុងអាងទន្លេមេគង្គក្រោមរបស់ MRC ដែលបានបោះពុម្ពផ្សាយកាលពីឆ្នាំ ២០០៩ (Preliminary Design Guidance 2009)។

បើទោះបីជាការចូលរួមរបស់សាធារណជនមិនមែនជាលក្ខខណ្ឌតម្រូវ សម្រាប់ដំណើរការនេះក៏ដោយ ប្រទេសជាសមាជិកបានឯកភាពគ្នា លើសារៈសំខាន់ និងការចូលរួមរបស់ភាគីពាក់ព័ន្ធនានា។ នៅថ្នាក់ជាតិ កិច្ចប្រជុំចែករំលែកព័ត៌មាន និងកិច្ចពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធថ្នាក់ជាតិ នឹងត្រូវរៀបចំឡើងទៅតាមយន្តការ និងការអនុវត្តក្នុងប្រទេសនីមួយៗ។ ដោយឡែកនៅថ្នាក់តំបន់វិញ កិច្ចប្រជុំចែករំលែកព័ត៌មាន និងពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធនៅថ្នាក់តំបន់ ក៏នឹងត្រូវរៀបចំឡើងផងដែរ។ ការចុះទៅតាមទីតាំងគម្រោង ក៏អាចធ្វើឡើងផងដែរ ប្រសិនបើចាំបាច់។

រាល់ការពិនិត្យបច្ចេកទេស ដែលបញ្ចូលលទ្ធផលរកឃើញពីកិច្ចប្រជុំចែករំលែកព័ត៌មាន និងពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធថ្នាក់ជាតិ នឹងត្រូវបង្ហាញទៅកាន់គណៈកម្មាធិការចម្រុះ។

បន្ទាប់មក ប្រទេសដែលទទួលបានការជូនដំណឹង នឹងដាក់ទម្រង់ឆ្លើយតបផ្លូវការ (Reply Form) របស់ខ្លួនទៅកាន់លេខាធិការដ្ឋាន MRC ដើម្បីឱ្យមានការកត់ត្រាយោបល់របស់ពួកគេ។

នៅដំណាក់កាលចុងក្រោយ គណៈកម្មាធិការចម្រុះ ត្រូវរៀបចំកិច្ចប្រជុំ ដើម្បីធ្វើការពិភាក្សាពីការពិគ្រោះយោបល់ជាមុនរបស់គម្រោងនេះ ក្នុងគោលបំណងឈានដល់ការព្រមព្រៀងមួយ ដើម្បីប្រើប្រាស់ទឹកឱ្យបានល្អប្រសើរបំផុត និងបង្ការការខ្ជះខ្ជាយទឹក ព្រមទាំងចេញសេចក្តីថ្លែងការណ៍មួយ ដែលរួមបញ្ចូលរាល់លក្ខខណ្ឌដែលបានឯកភាពគ្នា សម្រាប់គម្រោង។

បន្ទាប់ពីក្រុមការងារនៃគណៈកម្មាធិការចម្រុះសម្រេចយល់ស្រប អ្នកអាចទទួលបានព័ត៌មានស្ដីពីផែនទីបង្ហាញផ្លូវលម្អិតសម្រាប់ដំណើរការរយៈពេលប្រាំមួយខែនៅទីនេះ។

## ៧. តើលក្ខខណ្ឌដែលបានឯកភាពគ្នាទាំងនេះ អាចកែសម្រួលនៅពេលក្រោយទៀត ក្នុងអំឡុងពេលសាងសង់ ឬប្រតិបត្តិការគម្រោងដែរឬទេ? តើអាចមានការដាក់លក្ខខណ្ឌបន្ថែមអ្វីដែរឬទេ នៅដំណាក់កាលនេះ?

គេអាចធ្វើការពិចារណាលើលក្ខខណ្ឌទាំងនេះ សូម្បីតែបន្ទាប់ពីការពិគ្រោះយោបល់ជាមុនបានបញ្ចប់រួចទៅហើយក៏ដោយ។ នេះគឺដោយសារតែកិច្ចព្រមព្រៀងទន្លេមេគង្គឆ្នាំ ១៩៩៥ កំណត់និយមន័យ «ការឯកភាពគ្នា» លើលក្ខខណ្ឌនានា ត្រូវធ្វើឡើងក្រោមដំណើរការការពិគ្រោះយោបល់ជាមុនទៅតាមការឯកភាពគ្នាជារួម។

ផែនការសកម្មភាពរួម ដូចជា ផែនការសកម្មភាពរួមសម្រាប់គម្រោងប៉ាក់បេង និងប៉ាក់ឡាយ ក៏អាចជាយន្តការមួយ រៀបចំឡើងសម្រាប់ប្រទេសជូនដំណឹង ធ្វើការពិចារណាលើវិធានការបន្ថែម ហើយប្រសិនបើមានការឯកភាពពីគណៈកម្មាធិការចម្រុះ គឺសម្រាប់ឲ្យ MRC ធ្វើការពិនិត្យតាមដានការអនុវត្តអនុសាសន៍ផ្សេងៗ ។

## ៨. តើប្រទេសជាសមាជិកផ្សេងទៀត អាចធ្វើអ្វីខ្លះ ប្រសិនបើប្រទេសនោះរកឃើញនៅពេលក្រោយទៀតថា បរិស្ថានក្នុងដែនដីរបស់ខ្លួនបានទទួលរងផលប៉ះពាល់គួរឱ្យកត់សម្គាល់ដោយសារគម្រោងនេះ?

កិច្ចព្រមព្រៀងទន្លេមេគង្គឆ្នាំ១៩៩៥ ដាក់ចេញនូវក្របខ័ណ្ឌសម្រាប់ទប់ស្កាត់ និងបញ្ឈប់ផលប៉ះពាល់ដែលបង្កគ្រោះថ្នាក់។ ប្រទេសដែលជួបប្រទះនឹងផលប៉ះពាល់ទាំងនេះ គួរជូនដំណឹងដល់ MRC អំពីឧប្បត្តិហេតុដែលកើតមាន អមជាមួយនឹងភស្តុតាងដែលមានសុពលភាព ហើយប្រទេសដែលបង្កផលប៉ះពាល់ ចាំបាច់ត្រូវបញ្ឈប់មូលហេតុដែលនាំឱ្យមានគ្រោះថ្នាក់នេះជាបន្ទាន់ រហូតដល់មានការកំណត់ពីមូលហេតុពិតប្រាកដ។ កិច្ចព្រមព្រៀង ក៏បានចែងពីការទទួលខុសត្រូវរបស់រដ្ឋសមាជិក លើការខូចខាតនានា បន្ទាប់ពីកំណត់ដោយភាគីពាក់ព័ន្ធផងដែរ ស្របតាមគោលការណ៍ច្បាប់អន្តរជាតិ។

## ៩. តើគណៈកម្មាធិការចម្រុះ ចាំបាច់ត្រូវឈានដល់ការព្រមព្រៀងអំពីកិច្ចពិគ្រោះយោបល់ជាមុន សម្រាប់គម្រោងដែលបានលើកស្នើឡើងដែរឬទេ?

ទេ។

គណៈកម្មាធិការចម្រុះមិនចាំបាច់ ត្រូវឈានឲ្យដល់ការព្រមព្រៀង មុនពេលអនុវត្តគម្រោងប្រើប្រាស់ទឹកដែលបានស្នើនោះទេ។ នីតិវិធី PNPCA ចែងថា គណៈកម្មាធិការចម្រុះ ត្រូវខិតខំឈានឲ្យដល់ការ

ព្រមព្រៀងគ្នា។ ប្រសិនបើគណៈកម្មាធិការចម្រុះ មិនអាចឈានដល់ការព្រមព្រៀងទេ មតិយោបល់របស់គណៈកម្មាធិការនេះ នឹងត្រូវបញ្ចូលទៅក្នុងកំណត់ត្រាស្ដីពីការប្រើប្រាស់ទឹកដែលបានស្នើ សម្រាប់ជាមតិយោង នាពេលអនាគត។ សេចក្ដីសម្រេចចុងក្រោយថា តើត្រូវបន្តអនុវត្តគម្រោងឬអត់ គឺអាស្រ័យលើប្រទេសដែលលើកស្នើគម្រោងនេះ បន្ទាប់ពីប្រទេសនេះបានធ្វើការពិចារណាយ៉ាងម៉ត់ចត់ និងឆ្លើយតបដោយសុទ្ធចិត្តចំពោះរាល់ការព្រួយបារម្ភសមស្របរបស់ប្រទេសទទួលការជូនដំណឹង និងភាគីពាក់ព័ន្ធនានា។

## ១០. តើមានអ្វីកើតមានឡើង ប្រសិនបើគណៈកម្មាធិការចម្រុះមិនអាចឈានដល់ការឯកភាព អំពីដំណើរការការពិគ្រោះយោបល់ជាមុន ឬឯកភាពគ្នា លើលក្ខខណ្ឌដើម្បីសម្រេចឱ្យបាននូវការប្រើប្រាស់ទឹកឱ្យបានល្អបំផុត ឬបង្ការការខ្វះខាតទឹក?

ប្រសិនបើគណៈកម្មាធិការចម្រុះ ពុំអាចឈានដល់ការឯកភាព លើដំណើរការការពិគ្រោះយោបល់ជាមុននោះទេ គណៈកម្មាធិការនេះអាចបញ្ជូនករណីនេះទៅកាន់ស្ថាប័នអភិបាលកិច្ចដែលមានកម្រិតខ្ពស់ជាងរបស់ MRC នោះគឺក្រុមប្រឹក្សា MRC ដែលមានសមាសភាពជារដ្ឋមន្ត្រីក្រសួងទទួលបន្ទុកធនធានទឹក និងបរិស្ថាន មកពីប្រទេសជាសមាជិកទាំងបួន។ ប្រសិនបើក្រុមប្រឹក្សា ពុំអាចសម្រេចចិត្តលើបញ្ហានេះបានទេ ក្រុមប្រឹក្សាក៏អាចបញ្ជូនករណីនេះទៅកាន់រដ្ឋាភិបាលរបស់ប្រទេសទាំងបួន ដើម្បីធ្វើសេចក្ដីសម្រេចចិត្តទៅតាមផ្លូវការទូត។ ប្រសិនបើរដ្ឋាភិបាលនៃប្រទេសទាំងនេះយល់ថា មានភាពចាំបាច់ ដោយមានការឯកភាពគ្នា រដ្ឋាភិបាលនៃប្រទេសទាំងនេះ អាចស្នើសុំការផ្សះផ្សា និងបន្តនីតិវិធីនេះទៅតាមគោលការណ៍ច្បាប់អន្តរជាតិ។

## ១១. ហេតុអ្វីបានជា MRC ត្រូវការការពិគ្រោះយោបល់ជាមុន? តើដំណើរការនេះមានអត្ថប្រយោជន៍អ្វីខ្លះ?

សំណើគម្រោងប្រើប្រាស់ទឹក ដែលតម្រូវឱ្យមានការពិគ្រោះយោបល់ជាមុន ទំនងជាបង្កផលប៉ះពាល់គួរកត់សម្គាល់លើបរិស្ថាន និងប្រជាជន ដូច្នេះប្រទេសផ្សេងទៀតគួរមានឱកាសធ្វើការវាយតម្លៃ និងផ្ដល់យោបល់លើគម្រោងទាំងនេះ។

ដំណើរការការពិគ្រោះយោបល់ជាមុន មានគោលបំណងបង្ការមិនឱ្យមានប៉ះពាល់ពាល់អវិជ្ជមានឆ្លងដែនលើសហគមន៍តាមដងទន្លេ និងបរិស្ថាននៅខ្សែទឹកខាងលើ និងខ្សែទឹកខាងក្រោម។ ដំណើរការនេះ ក៏ សំដៅសម្រេចឱ្យបាន ការប្រើប្រាស់ទឹកឱ្យបានល្អបំផុត និងជៀសវាងការខ្វះខាតទឹក។

កន្លងមក MRC បានដំណើរការ ការពិគ្រោះយោបល់ជាមុនចំនួនប្រាំរួចមកហើយ គឺសម្រាប់គម្រោងទំនប់វារីអគ្គិសនីសាយ៉ាបូរី ដនសាហុង ប៉ាក់បេង ប៉ាក់ឡាយ និងលួងប្រាបាង ដែលទំនប់ទាំងនេះ

សុទ្ធតែមានទីតាំងនៅតាមដងទន្លេមេគង្គមេ ក្នុងប្រទេសឡាវ។ ករណីទាំងនេះបង្ហាញពីភាពជឿនលឿននៃការអនុវត្តកិច្ចព្រមព្រៀងទន្លេមេគង្គឆ្នាំ១៩៩៥ និងភាពជឿនលឿនរបស់ MRC ខ្លួនឯង ដែលបញ្ជាក់ពីជាស្មារតីមេគង្គនៃកិច្ចសហប្រតិបត្តិការដ៏អស្ចារ្យរបស់ប្រទេសជាសមាជិក ។

សម្រាប់ទំនប់សាយ៉ាបូរី ដំណើរការនេះបានជំរុញឱ្យរដ្ឋាភិបាលឡាវ និងក្រុមហ៊ុនអភិវឌ្ឍន៍ ធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដោយខ្លួនឯង និងវិនិយោគថវិការាប់រយលានដុល្លារ ដើម្បីកែសម្រួលប្លង់សាងសង់ទំនប់ ឲ្យឆ្លើយតបចំពោះបញ្ហាបម្លាស់ទីត្រី និងដីល្បាប់ ដែលជាបញ្ហាគោលពីរ ដែលបានលើកឡើងអំឡុងពេលការពិគ្រោះយោបល់ជាមុននេះ។ គម្រោងដនសាហុង ក៏មានភាពរីកចម្រើនស្រដៀងគ្នាផងដែរ។

ក្នុងករណីទំនប់ប៉ាក់បេង និងប៉ាក់ឡាយ គណៈកម្មាធិការចម្រុះបានឈានដល់ការព្រមព្រៀងនៅចុងដំណើរការការពិគ្រោះយោបល់ជាមុន ដែលមានរយៈពេលប្រាំមួយខែ។ គណៈកម្មាធិការរួមបានចេញនូវសេចក្តីថ្លែងការណ៍មួយ និងបន្ទាប់មកទៀតនូវផែនការសកម្មភាពរួមមួយ ដើម្បីដាក់ចេញនូវយន្តការសម្រាប់បន្តផ្តល់ព័ត៌មានគ្រឡប់ ផ្លោះប្តូរទិន្នន័យ និងចែករំលែកចំណេះដឹង រវាងប្រទេសឡាវ និង MRC ពាក់ព័ន្ធនឹងការរៀបចំប្លង់សាងសង់ ការសាងសង់ និងប្រតិបត្តិការបន្តរបស់គម្រោងនេះ។

ប្រសិនបើគ្មានដំណើរការការពិគ្រោះយោបល់ជាមុនទេ នឹងមិនមានការចែករំលែកព័ត៌មាន និងកិច្ចពិគ្រោះយោបល់ជាមុនដោយចំហរដែរ សម្រាប់គម្រោងនានានៅតាមប្រទេសដែលមានអធិបតេយ្យភាព។ ហើយប្រសិនបើគ្មានដំណើរការនេះទេ ក៏ពុំមានឳកាសកែលម្អគម្រោង តាមរយៈការផ្តល់អនុសាសន៍ដោយឯករាជ្យដែរ។ ដំណើរការនេះ តម្រូវឱ្យមានការវាយតម្លៃជាលក្ខណៈវិទ្យាសាស្ត្រ និងការសម្របសម្រួលដោយក្រុមអ្នកជំនាញអព្យាក្រិតមកពីលេខាធិការដ្ឋាន MRC។ ការវាយតម្លៃបែបនេះ ធានាបាននូវតុល្យភាពរវាងផលប្រយោជន៍របស់ប្រទេសជាសមាជិកទាំងបួន និងនិរន្តរភាពផ្នែកសង្គម និងបរិស្ថាននៃតំបន់អាងទន្លេមេគង្គ។

ទោះបីមានទស្សនៈផ្សេងៗពីគ្នាលើគម្រោងដែលបានស្នើក៏ដោយ ដំណើរការនេះគឺមានសារៈសំខាន់ណាស់ ដោយសារថា៖

- វាចែករំលែកព័ត៌មាន និងទិន្នន័យយ៉ាងទូលំទូលាយពីហេដ្ឋារចនាសម្ព័ន្ធគម្រោងសំខាន់ៗជាសាធារណៈ
- វាផ្តល់នូវវេទិកាផ្លូវការ ស្របច្បាប់ និងសុវត្ថិភាពមួយសម្រាប់ប្រទេស និងភាគីពាក់ព័ន្ធទាំងអស់ ដើម្បីបញ្ចេញមតិយោបល់ និងសំណើខុសៗគ្នា បន្ទាប់ពីធ្វើការពិចារណាយ៉ាងពេញលេញលើព័ត៌មានដែលបានផ្តល់ឲ្យ
- វាផ្តល់លទ្ធភាពដល់អ្នកជំនាញមកពី MRC ប្រទេសជាសមាជិក ក៏ដូចជាអង្គការមិនមែនរដ្ឋាភិបាលដ៏ទៃទៀត ក្នុងការពិនិត្យគម្រោងឡើងវិញដោយឯករាជ្យ

- វានាំឲ្យមានការកែសម្រួល និងការកែលំអជាក់ស្តែងនៃគម្រោងដែលបានស្នើ
- វាបង្កើតឲ្យមានយន្តការផែនការសកម្មភាពរួមមួយ ដើម្បីបន្តចូលរួមអភិវឌ្ឍគម្រោងបន្ថែមទៀត ក្រោយពេលដំណើរការនីតិវិធី PNPCA រួមទាំងការតាមដានផលប៉ះពាល់រួមគ្នាផងដែរ។

ដំណើរការទាំងនេះធ្វើឲ្យប្រទេសដែលលើកស្នើគម្រោងបន្តការចូលរួម និងមានគណនេយ្យភាព។ អវត្តមានរបស់ MRC និងនីតិវិធី PNPCA អាចឲ្យគម្រោងតាមអាងទន្លេមេគង្គ អនុវត្តទៅតាមអ្វីដែលគេចង់បាន ដោយមិនមានព័ត៌មាន ឬការពិនិត្យឡើងវិញពីសំណាក់សាធារណជន។

## ១២. តើនរណាខ្លះ ត្រូវចូលរួមក្នុងដំណើរការការពិគ្រោះយោបល់ជាមុននេះ?

ដំណើរការការពិគ្រោះយោបល់ជាមុន ធ្វើឡើងដោយគណៈកម្មាធិការចម្រុះ នឹងមានការគាំទ្រពីលេខាធិការដ្ឋាន MRC តាមរយៈការបំពេញមុខងារបច្ចេកទេស និងមុខងាររដ្ឋបាល។ គណៈកម្មាធិការជាតិទន្លេមេគង្គរបស់ប្រទេសនីមួយៗ និងលេខាធិការដ្ឋាននៃគណៈកម្មាធិការនេះ បំពេញមុខងាររដ្ឋបាល និងមុខងារសម្របសម្រួលក្នុងប្រទេស និងផ្តល់ការគាំទ្រដល់គណៈកម្មាធិការចម្រុះ ក្នុងការអនុវត្តសកម្មភាពពាក់ព័ន្ធនានា។

ក្រុមការងារនៃគណៈកម្មាធិការចម្រុះបំពេញតួនាទីជាស្ថាប័នផ្តល់ប្រឹក្សាបច្ចេកទេស ដើម្បីជួយដល់គណៈកម្មាធិការចម្រុះ ក្នុងអំឡុងពេលអនុវត្តដំណើរការ PNPCA។ ក្រុមការងារនៃគណៈកម្មាធិការចម្រុះដែលមានការគាំទ្រពីលេខាធិការដ្ឋាន និងធ្វើការពិនិត្យលើទិដ្ឋភាពនានា ដូចជា លំហូរទឹក សុវត្ថិទំនប់ បម្លាស់ទីត្រី លំហូរដីល្បាប់ ការធ្វើនាវាចរណ៍ និងផលប៉ះពាល់លើបរិស្ថាន និងសង្គម សេដ្ឋកិច្ច។

អង្គការសង្គមស៊ីវិល និងសាធារណជនទូទៅ នឹងត្រូវបានគណៈកម្មាធិការជាតិទន្លេមេគង្គតាមប្រទេសនីមួយៗ លើកទឹកចិត្តឱ្យចូលរួមក្នុងការចែករំលែកព័ត៌មាន និងការពិគ្រោះយោបល់ជាមួយនឹងភាគីពាក់ព័ន្ធនៅក្នុងប្រទេស។

នៅថ្នាក់តំបន់ នឹងមានការរៀបចំកិច្ចពិគ្រោះយោបល់ជាមួយនឹងភាគីពាក់ព័ន្ធនៅថ្នាក់តំបន់ចំនួនពីរលើក សម្រាប់គម្រោងទំនប់វារីអគ្គិសនីសាណាខាំ ដែលអំពាវនាវឱ្យមានការចូលរួមពីសាធារណជនទូទៅ។

## ១៣. តើលេខាធិការដ្ឋាន MRC មានតួនាទីអ្វីខ្លះ នៅក្នុងដំណើរការនេះ?

លេខាធិការដ្ឋាន MRC នឹងជួយដល់ប្រទេសជាសមាជិកក្នុងការវាយតម្លៃស្ថានភាពបច្ចេកទេសផ្សេងៗនៃគម្រោង ព្រមទាំងសម្របសម្រួលកិច្ចប្រជុំរបស់គណៈកម្មាធិការចម្រុះ។

លេខាធិការដ្ឋាន MRC រួមនឹងលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិទន្លេមេគង្គ នៅតាមបណ្ដាប្រទេសជាសមាជិកនីមួយៗ នឹងសម្របសម្រួលកិច្ចប្រជុំពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធនៅថ្នាក់ជាតិ និងថ្នាក់តំបន់ ដើម្បីប្រមូលយោបល់ និងការព្រួយបារម្ភពីភាគីពាក់ព័ន្ធ និងភាគីដែលមានចំណាប់អារម្មណ៍ដទៃទៀតលើករណីនេះ ដាក់ជូនប្រទេសដែលលើកសំណើ ធ្វើការពិចារណា។ លេខាធិការដ្ឋាន MRC នឹងសម្របសម្រួលកិច្ចពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធនានាដោយសុទ្ធចិត្ត និងចងក្រងឯកសារពីទស្សនៈរបស់ពួកគេជាលក្ខណៈប្រព័ន្ធ និងបង្ហាញពីរបៀបដែលស្ថាប័នអភិបាលកិច្ចរបស់ MRC ពិចារណាយោបល់ទាំងនេះ និងផ្ដល់ព័ត៌មានត្រឡប់ទៅឱ្យភាគីពាក់ព័ន្ធទាំងនោះវិញ។

បន្ទាប់ពីកិច្ចពិគ្រោះយោបល់ត្រូវបានបញ្ចប់ លេខាធិការដ្ឋានអាចបន្តផ្ដល់ជាតុចូលផ្នែកបច្ចេកទេសលើគម្រោង ប្រសិនបើចាំបាច់។

## ១៤. តើបញ្ហាអ្វីខ្លះ ដែលនឹងត្រូវលើកយកមកធ្វើការពិចារណា ក្នុងអំឡុងពេលត្រួតពិនិត្យលើលក្ខណៈបច្ចេកទេសរបស់គម្រោងផ្អែកតាមឯកសារដែលផ្ញើមក?

ការត្រួតពិនិត្យបច្ចេកទេស នឹងពិនិត្យមើលលើទស្សនទានជារួមនៃគម្រោងដែលបានស្នើ ដោយផ្អែកលើការសិក្សាលទ្ធភាពគម្រោងដែលភ្ជាប់មកជាមួយ ព្រមទាំងការវាយតម្លៃហេតុប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម។

ការពិនិត្យនេះ នឹងវាយតម្លៃលើគម្រោង ដោយធៀបនឹងសេចក្ដីណែនាំ ស្ដីពីការរៀបចំប្លង់សាងសង់ទំនប់បឋមសម្រាប់គម្រោងដែលបានស្នើតាមដងទន្លេមេ ក្នុងតំបន់អាងទន្លេមេគង្គក្រោម ដែលបានបោះពុម្ពផ្សាយនៅឆ្នាំ ២០០៩ (PDG 2009) និងកំណត់ពីចំណុចខ្វះខាត និងការកែសម្រួលនានា ប្រសិនបើចាំបាច់។ ឯកសារ PDG ២០០៩ ផ្ដល់ការណែនាំអំពីគោលដៅអនុវត្ត គោលការណ៍រៀបចំប្លង់សាងសង់ និងប្រតិបត្តិការសម្រាប់បង្កើតយន្តការកាត់បន្ថយផលបប៉ះពាល់ ក៏ដូចជាការពិនិត្យតាមដានលើភាពអនុលោម និងការគ្រប់គ្រងបែបបន្សាំ។ ការពិនិត្យនេះក៏ដោះស្រាយបញ្ហាជាក់លាក់មួយចំនួន ដែលបានសម្រេចដោយក្រុមការងារនៃគណៈកម្មាធិការចម្រុះផងដែរ។

## ១៥. តើការបន្តធ្វើបច្ចុប្បន្នភាពឯកសារណែនាំស្ដីពីការរៀបចំប្លង់សាងសង់ទំនប់បឋមសម្រាប់គម្រោងដែលស្នើតាមដងទន្លេមេ ក្នុងតំបន់អាងទន្លេគង្គក្រោម (PDG 2020) ចូលរួមចំណែកអ្វីខ្លះ ដល់ដំណើរការការពិគ្រោះយោបល់ជាមុននេះ?

ការពិនិត្យបច្ចេកទេស នឹងយោងតាមឯកសារ PDG 2009 ភាគច្រើន ព្រោះថានេះគឺជាក្របខ័ណ្ឌដែលបានអនុម័តតែមួយគត់ ដែលអាចប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការពិនិត្យឡើងវិញ។ ទោះជាយ៉ាងនេះក្ដី នឹងមានកិច្ចខិតខំប្រឹងប្រែង ដើម្បីផ្ដល់យោបល់ បញ្ចូនមតិ និងលើកជាសំណូមពរចំពោះក្រុមហ៊ុន

អភិវឌ្ឍន៍គម្រោង និងរដ្ឋាភិបាលឡាវអំពីចំណុចខ្វះខាត និងចំណុចមិនច្បាស់លាស់ ដែលមានក្នុងឯកសារ PDG 2009 ដោយ ការបំពេញបន្ថែម និងយោងលើឯកសារណែនាំស្តីពីការរៀបចំប្លង់សាងសង់ទំនប់បឋម ឆ្នាំ ២០២០ រួមជាមួយនឹងចំណេះដឹងបច្ចុប្បន្នភាពរបស់ស្ថាប័ន។

## **១៦. តើអង្គការស្ថាប័ន ឬភាគីពាក់ព័ន្ធនានា នឹងចូលរួមក្នុងកិច្ចពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ ឬកិច្ចប្រជុំចែករំលែកព័ត៌មាន បានដោយដូចម្តេចខ្លះ?**

ការទទួលខុសត្រូវលើការរៀបចំកិច្ចពិគ្រោះយោបល់ ឬកិច្ចប្រជុំចែករំលែកព័ត៌មានក្នុងប្រទេស គឺជាភារកិច្ចរបស់គណៈកម្មាធិការជាតិទន្លេមេគង្គនីមួយៗ ដែលជាស្ថាប័នសម្របសម្រួលរបស់រដ្ឋាភិបាលនៃប្រទេសជាសមាជិកនីមួយៗ ដែលសម្របសម្រួលដោយលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិទន្លេមេគង្គ។ លេខាធិការដ្ឋាន MRC នឹងផ្តល់ការគាំទ្របច្ចេកទេស។

បើពិចារណាលើបទពិសោធណ៍ពីគម្រោងទាំងបួនកន្លងមក ដែលមានសាយ៉ាបូរី ដនសាហុង ប៉ាក់បេង និងប៉ាក់ឡាយ ក៏ដូចជាគម្រោងលួងប្រាបាងនាពេលថ្មីៗនេះ លេខាធិការដ្ឋាន MRC បានចាប់ផ្តើមជំរុញឱ្យមានការចូលរួមពីភាគីពាក់ព័ន្ធនានា តាំងពីដំបូងក្នុងដំណើរការការពិគ្រោះយោបល់ជាមុននេះ។ បន្ថែមពីនេះ ក៏មានការចែករំលែកព័ត៌មានយ៉ាងទូលំទូលាយ និងប្រកបដោយតម្លាភាព លើគេហទំព័ររបស់ MRC ផងដែរ។

លេខាធិការដ្ឋាន MRC ក៏បានដឹងពីភាពចាំបាច់ក្នុងការផ្តល់ពេលវេលាឱ្យបានគ្រប់គ្រាន់ ដើម្បីឱ្យសាធារណជនត្រួតពិនិត្យលើឯកសារគម្រោង។ ដោយហេតុនេះ លេខាធិការដ្ឋានក៏បានបង្ហោះឯកសារគម្រោងលើគេហទំព័រពិសេសមួយ សម្រាប់គម្រោងទំនប់វារីអគ្គិសនីសាណាខាំ។

លោក អ្នកអាចចូលមើលឯកសារទាំងនេះ តាមគេហទំព័រ៖
http://www.mrcmekong.org/topics/pnpca-prior-consultation/sanakham-hydropower-project/

នៅក្នុងគេហទំព័រដដែលនេះ លេខាធិការដ្ឋានបានចងក្រងឯកសារសង្ខេបស្តីពីទិដ្ឋភាពទូទៅនៃឯកសារបច្ចេកទេសជាច្រើនបញ្ចូលគ្នា ដែលមានកម្រាស់ ២៩ទំព័រ។ ក្នុងពេលឆាប់ៗនេះ ឯកសារសង្ខេបនេះនឹងមានជាបួនភាសាជាតិ សម្រាប់សាធារណជនប្រើប្រាស់ឲ្យបានកាន់តែទូលំទូលាយ។

ឯកសារពាក់ព័ន្ធដទៃទៀត ក៏នឹងត្រូវរៀបចំសម្រាប់ ដំណើរការនេះ ឱ្យបានទាន់ពេលវេលាផងដែរ ដែលរួមមាន បទបង្ហាញ និងព័ត៌មានសង្ខេបអំពីគម្រោងដែលបានស្នើជាដើម។

លើសពីនេះ នឹងមានកិច្ចប្រជុំពិគ្រោះយោបល់ជាមួយតួអង្គពាក់ព័ន្ធចំនួនពីរនៅថ្នាក់តំបន់ និងកិច្ចប្រជុំចែករំលែកព័ត៌មាន និងពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធជាច្រើន សម្រាប់សហគមន៍ដែលរងផលប៉ះពាល់នៅកម្រិតប្រទេស។ ដើម្បីសម្របសម្រួលឱ្យមានការចូលរួមឱ្យបានទូលំទូលាយ ពីភាគីពាក់ព័ន្ធនានា អ្នកចូលរួមពីគ្រប់វិស័យទាំងអស់ ដូចជាអង្គការមិនមែនរដ្ឋាភិបាល អង្គការតាមសហគមន៍

ស្ថាប័នស្រាវជ្រាវ ស្ថាប័នសិក្សា ក្រុមហ៊ុនអភិវឌ្ឍន៍ អ្នកសារព័ត៌មាន និងភាគីពាក់ព័ន្ធដទៃទៀត នឹងត្រូវបានស្វាគមន៍ឱ្យចូលរួមក្នុងដំណើរការនេះ។ MRC នឹងផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុដល់អ្នកចូលរួមមកពីអង្គការស្ថាប័ន ដែលពាក់ព័ន្ធយ៉ាងខ្លាំងជាមួយនឹងដំណើរការនេះ ប្រសិនបើពួកគេជួបប្រទះនឹងការលំបាកផ្នែកហិរញ្ញវត្ថុ។

MRC បំពេញភារកិច្ចរបស់ខ្លួន ដោយប្រើប្រាស់វិធីសាស្ត្របែបចូលរួម តាមរយៈកិច្ចសហប្រតិបត្តិការ ការចូលរួមចំណែកពីភាគីពាក់ព័ន្ធ និងសហគមន៍ក្នុងអំឡុងពេលអនុវត្ត។ MRC ផ្តល់តម្លៃខ្លាំងលើមតិយោបល់ និងការព្រួយបារម្ភរបស់ភាគីពាក់ព័ន្ធ និងភាគីដែលមានចំណាប់អារម្មណ៍លើសុខុមាលភាពរបស់ប្រជាពលរដ្ឋក្នុងអាងទន្លេមេគង្គ។ លេខាធិការដ្ឋាន MRC កំពុងខំប្រឹងឲ្យអស់ពីលទ្ធភាពរបស់ខ្លួន ផ្តល់ការគាំទ្រដល់ប្រទេសនៅតាមតំបន់ទន្លេមេគង្គ ដើម្បីប្រែក្លាយគោលនយោបាយរបស់ខ្លួន ឲ្យទៅជាការអនុវត្តជាក់ស្តែង សំដៅធានាឱ្យមានការអភិវឌ្ឍ និងការគ្រប់គ្រងអាងទន្លេមេគង្គប្រកបដោយចីរភាព។

ក្នុងអំឡុងដំណើរការការពិគ្រោះយោបល់ជាមុន យើងខិតខំឱ្យអស់ពីសមត្ថភាព ដើម្បីធ្វើឲ្យយុទ្ធសាស្ត្រចូលរួមពីភាគីពាក់ព័ន្ធរបស់ MRC ឲ្យបានកាន់តែប្រសើរ តាមរយៈដំណើរការអនុវត្តជាប់ជាប្រចាំរួមមាន ការចែករំលែកព័ត៌មាន វេទិកា និងកិច្ចពិគ្រោះយោបល់ជាមួយនឹងភាគីពាក់ព័ន្ធជាដើម។ MRC ស្វាគមន៍រាល់យោបល់ និងមតិត្រឡប់ពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ តាមរយៈប្រអប់ផ្តល់យោបល់ដ៏សកម្មរបស់យើង ដែលមាននៅលើគេហទំព័រ MRC និងអាចចូលមើលនៅទីនេះ៖
http://www.mrcmekong.org/stakeholder-consultations

## ១៧. តើក្រុមការងាររបស់គណៈកម្មាធិការចម្រុះមានតំណាងអង្គការសង្គមស៊ីវិលដែរឬទេ?

ទេ។

ក្រុមការងារនៃគណៈកម្មាធិការចម្រុះមិនមានសមាជិកតំណាងពីអង្គការសង្គមស៊ីវិលទេ។ ក្រុមការងារនេះ គឺជាស្ថាប័នផ្តល់ប្រឹក្សាបច្ចេកទេសរបស់រដ្ឋាភិបាលជាសមាជិកទាំងបួន និងត្រូវបានបង្កើតឡើង ដើម្បីផ្តល់ការណែនាំដល់លេខាធិការដ្ឋាន MRC ក្នុងការសម្របសម្រួលដំណើរការ និងពិភាក្សាពីបញ្ហាដែលកំពុងកើតមាន។

ក្រុមការងារនេះ ក៏មានតួនាទីគាំទ្រគណៈកម្មាធិការចម្រុះរបស់ MRC ក្នុងការអនុវត្តនីតិវិធី PNPCA និងផ្តល់ការណែនាំចាំបាច់ដល់លេខាធិការដ្ឋាន MRC ពាក់ព័ន្ធនឹងគម្រោងជូនដំណឹងទាំងអស់ ត្រូវឆ្លងកាត់ការពិគ្រោះយោបល់ជាមុន ឬការព្រមព្រៀងស្របទៅតាមគោលការណ៍ និងវិធានការដែលបានចែងក្នុងកិច្ចព្រមព្រៀងទន្លេមេគង្គឆ្នាំ ១៩៩៥។ ការបង្កើតក្រុមការងារនេះ មានបញ្ជាក់នៅក្នុងនីតិវិធីរបស់ MRC ។

ក្រុមការងារនេះ រួមមានសមាសភាពតំណាងចំនួនបួនរូប មកពីប្រទេសនីមួយៗនៃប្រទេសតាមអាងទន្លេមេគង្គក្រោម និងដោយមានលេខាធិការដ្ឋាន MRC ផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងផ្នែករដ្ឋបាល ។

ទោះជាយ៉ាងណាក៏ដោយ មតិយោបល់ផ្លូវការ និងមតិសាធារណជនដ៏ទៃទៀត ដែលបានកត់ត្រាក្នុងវេទិកាសម្រាប់ភាគីពាក់ព័ន្ធថ្នាក់តំបន់ កិច្ចប្រជុំថ្នាក់ជាតិ និងបណ្តាញទំនាក់ទំនងផ្សេងៗទៀត នឹងត្រូវលើកឡើងនៅក្នុងកិច្ចប្រជុំសម្រាប់ក្រុមការងារ និងគណៈកម្មាធិការចម្រុះ។

## ១៨. តើ MRC ប្រើប្រាស់យោបល់រួមរបស់ក្រុមភាគីពាក់ព័ន្ធក្នុងដំណើរការការពិគ្រោះយោបល់ជាមុនដោយរបៀបណា?

«តារាង ម៉ាទ្រីសយោបល់» ឆ្លុះបញ្ចាំងពីធាតុចូល ទស្សនៈយល់ឃើញ និងមតិនានារបស់ភាគីពាក់ព័ន្ធ ដែលនឹងត្រូវចងក្រងជាឯកសារ ដាក់ក្នុងរបាយការណ៍ស្តីពីការពិគ្រោះយោបល់ជាមួយនឹងភាគីពាក់ព័ន្ធ។ របាយការណ៍នេះ នឹងត្រូវលើកយកមកធ្វើការពិចារណាក្នុងអំឡុងពេលវាយតម្លៃលើគម្រោងនេះ។

ទទួលបានពីរបាយការណ៍ចែករំលែកព័ត៌មាននៅថ្នាក់តំបន់ លទ្ធផលរកឃើញ និងអនុសាសន៍ រួមជាមួយនឹងរបាយការណ៍ស្តីពីការចែករំលែព័ត៌មានថ្នាក់ជាតិ នឹងត្រូវបញ្ចូលទៅក្នុងរបាយការណ៍ត្រួតពិនិត្យបច្ចេកទេស (Technical Review Report) ក៏ដូចជាបង្ហាញទៅកាន់ស្ថាប័នអភិបាលកិច្ចរបស់ MRC ដើម្បីយកទៅធ្វើការពិចារណាក្នុងអំឡុងពេលចរចារអំពីលក្ខខណ្ឌនានាសម្រាប់គម្រោងនេះ។

## ១៩. តើមានការផ្តល់ព័ត៌មានអំពីគម្រោងច្រើនកម្រិតណា ដល់ភាគីពាក់ព័ន្ធ និងសាធារណជនទូទៅ?

MRC បានបង្ហាញឯកសារគម្រោងទាំងអស់ដែលបានស្នើ នៅលើគេហទំព័ររបស់ខ្លួន ដែលសាធារណៈជនទូទៅអាចប្រើប្រាស់បាន។ ឯកសារទាំងនេះរួមមាន ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមឆ្លងដែន និងការវាយតម្លៃផលប៉ះពាល់រួម ការវាយតម្លៃផលប៉ះពាល់ផ្នែកបរិស្ថាន ផែនការគ្រប់គ្រង និងតាមដានផ្នែកបរិស្ថាន ការវាយតម្លៃហេតុប៉ះពាល់សង្គម ផែនការគ្រប់គ្រង និង តាមដានសង្គម រួមជាមួយនឹងផែនការអភិវឌ្ឍន៍ការផ្លាស់ទីលំនៅថ្មី។ គេហទំព័រនេះ ក៏មានរបាយការណ៍ស្តីពីការស្ថានភាពវិស្វកម្ម និងគំនូសព្រាង ដែលបានបង្ហោះក្នុងគេហទំព័ររបស់ MRC តាមៈ http://www.mrcmekong.org/topics/pnpca-prior-consultation/sanakham-hydropower-project/

ឯកសារដែលមាននាពេលបច្ចុប្បន្ន និងឯកសារដែលនឹងត្រូវរៀបចំឡើងនាពេលអនាគតពាក់ព័ន្ធនឹងការពិគ្រោះយោបល់ទុកជាមុននេះ ក៏នឹងត្រូវបង្ហាញលើគេហទំព័រដដែលនេះដែរ។ ឯកសារទាំងនេះរួមមាន ការត្រួតពិនិត្យផ្នែកបច្ចេកទេសរបស់ MRC លើឯកសារគម្រោង របាយការណ៍ពិគ្រោះយោបល់ជាមួយ

នឹងភាគីពាក់ព័ន្ធ និងទម្រង់ឆ្លើយតបជាផ្លូវការដែលធ្វើដោយប្រទេសទទួលបានការជូនដំណឹងទាំងបី គឺប្រទេសកម្ពុជា ថៃ និងវៀតណាម។

## ២០. តើការសាងសង់អាចចាប់ផ្តើមក្នុងអំឡុងកិច្ចពិគ្រោះយោបល់ជាមុនដែរឬទេ?

ទេ។

ក្រោមដំណើរការ PNPCA ប្រទេសជូនដំណឹង មិនអាចអនុវត្តគម្រោងប្រើប្រាស់ធនធានទឹក ដែលបានស្នើ ដោយមិនផ្តល់ឱកាសឱ្យប្រទេសដែលទទួលបានការជូនដំណឹង ធ្វើការពិភាក្សា និងវាយតម្លៃលើគម្រោងនេះឡើយ។

## ២១. តើលទ្ធផលនៃការពិគ្រោះយោបល់ជាមុន សម្រាប់គម្រោងណាមួយ អាចប្រើប្រាស់ជាបទដ្ឋានសម្រាប់គម្រោងនាពេលអនាគត ដែលដាក់ស្នើឱ្យឆ្លងកាត់ដំណើរការដូចគ្នានេះដែរឬទេ?

ទេ។

ការរៀបចំដំណើរការការពិគ្រោះយោបល់ជាមុន គឺផ្អែកលើករណីនីមួយៗនៃគម្រោងអភិវឌ្ឍន៍លើដងទន្លេមេដែលបានស្នើ។ ប្រសិនបើនាពេលអនាគត គម្រោងដែលមានលក្ខណៈស្រដៀងគ្នានេះ ត្រូវបានដាក់ជូន MRC សម្រាប់ឆ្លងកាត់ដំណើរការការពិគ្រោះយោបល់ជាមុន លទ្ធផលនៃការពិគ្រោះយោបល់កន្លងមក នឹងមិនប៉ះពាល់ដល់គម្រោងថ្មីដែលបានស្នើនេះឡើយ។ ក៏ប៉ុន្តែ ព័ត៌មាន និងចំណេះដឹងដែលបានចែករំលែកក្នុងអំឡុងដំណើរការការពិគ្រោះយោបល់ជាមុនកន្លងមក នឹងផ្តល់ជាប្រយោជន៍ដល់គម្រោងនាពេលអនាគត និងអាចប្រើប្រាស់ជាផ្នែកមួយនៃមូលដ្ឋានព័ត៌មានសម្រាប់ធ្វើការវាយតម្លៃ។

ក្នុងឆ្នាំ ២០១៦ MRC បានត្រួតពិនិត្យលើការអនុវត្ត PNPCA ដែលបានអនុម័តក្រោមកិច្ចព្រមព្រៀងទន្លេមេគង្គឆ្នាំ១៩៩៥ និងបានប្រមូលចងក្រងមេរៀនសំខាន់ៗមួយចំនួន សម្រាប់ប្រើប្រាស់ជាឯកសារយោងនាពេលអនាគត។ មេរៀនសំខាន់ៗទាំងនេះរួមមាន៖

(១) ការបញ្ជាក់ឱ្យកាន់តែច្បាស់ជាងមុន ពាក់ព័ន្ធនឹងការចាប់ផ្តើម និងការបញ្ចប់ដំណើរការការពិគ្រោះយោបល់ជាមុន

(២) ដំណើរការសម្រាប់ត្រួតពិនិត្យ និងឯកភាពលើភាពគ្រប់គ្រាន់នៃឯកសារដែលបានទទួលសម្រាប់ការពិគ្រោះយោបល់ជាមុន

(៣) ភាពច្បាស់លាស់ពីតួនាទីរបស់ភាគីទាំងអស់ ដែលទទួលខុសត្រូវលើការអនុវត្តដំណើរការ PNPCA

(៤) ការរៀបចំបង្ហាញព័ត៌មានគម្រោងឱ្យបានសមស្រប ដើម្បីជំរុញឱ្យមានការចូលរួមពីភាគីពាក់ព័ន្ធប្រកបដោយប្រសិទ្ធិភាព

(៥) ភាពច្បាស់លាស់ពីតួនាទីនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន និង

(៦) ការរៀបចំ «សេចក្តីអត្ថាធិប្បាយបច្ចេកទេស» អំពីលក្ខខណ្ឌនៃដំណើរការ PNPCA ដើម្បីបំពេញបន្ថែមលើគោលការណ៍ណែនាំស្តីពីការអនុវត្តដំណើរការ PNPCA នាពេលបច្ចុប្បន្ន តាមរយៈការដាក់បញ្ញត្តិសំខាន់ៗនៃដំណើរការ PNPCA នៅក្នុងបរិបទការអនុវត្តនៅកម្រិតអន្តរជាតិ ។

ដំណើការការពិគ្រោះយោបល់ជាមុន សម្រាប់គម្រោងទំនប់វារីអគ្គិសនីប៉ាក់បេង ប៉ាក់ឡាយ និងលួងប្រាបាង បានធ្វើការពិចារណាលើមេរៀនដែលទទួលបានទាំងនេះ ក្នុងអំឡុងពេលអនុវត្ត។ យើងរំពឹងថា នឹងមានការអនុវត្តដូចគ្នា ក្នុងករណីគម្រោងសាណាខាំ។

## ២២. តើលទ្ធផលរកឃើញពីការសិក្សារបស់ក្រុមប្រឹក្សា (ការសិក្សាអំពីការគ្រប់គ្រង និងការអភិវឌ្ឍតំបន់ទន្លេមេគង្គ ប្រកបដោយចីរភាព រាប់បញ្ចូលទាំងផលប៉ះពាល់ដែលបង្កឡើងដោយគម្រោងវារីអគ្គិសនីតាមដងទន្លេមេ) ចូលរួមចំណែកដូចម្តេចខ្លះចំពោះដំណើរការការពិគ្រោះយោបល់ជាមុននេះ?

គោលបំណងសំខាន់នៃការសិក្សារបស់ក្រុមប្រឹក្សា គឺដើម្បីបង្កើនសមត្ថភាព MRC ក្នុងការផ្តល់ប្រឹក្សាដល់ប្រទេសជាសមាជិកអំពីផលប៉ះពាល់វិជ្ជមាន និងអវិជ្ជមាន ដែលការអភិវឌ្ឍធនធានទឹកមានលើប្រជាពលរដ្ឋ សេដ្ឋកិច្ច និងបរិស្ថានក្នុងតំបន់អាងទន្លេមេគង្គ ដោយផ្តោតការយកចិត្តទុកដាក់លើការបង្កើនការយល់ដឹងអំពីការអភិវឌ្ឍទន្លេមេគង្គប្រកបដោយចីរភាព។

ការសិក្សារបស់ក្រុមប្រឹក្សានេះ មានវិសាលភាពគ្របដណ្តប់លើវិស័យពាក់ព័ន្ធនឹងធនធានទឹកទាំងអស់ ដូចជាធារាសាស្ត្រ ការប្រើប្រាស់ដីកសិកម្ម ការនេសាទ នាវាចរណ៍ ការប្រើប្រាស់ទឹកជាលក្ខណៈគ្រួសារ និងជាលក្ខណៈឧស្សាហកម្ម និងវារីអគ្គិសនី ដោយផ្តោតការយកចិត្តទុកដាក់ ជាពិសេសលើគម្រោងអភិវឌ្ឍន៍តាមដងទន្លេមេ។ ការសិក្សានេះ ក៏ធ្វើការពិចារណាលើជំនាញសំខាន់ៗផ្សេងទៀត ដូចជាបញ្ហាជលសាស្ត្រ និងបញ្ហាពាក់ព័ន្ធជីវចម្រុះ បរិស្ថាន សង្គម និងសេដ្ឋកិច្ច ម៉ាក្រូសេដ្ឋកិច្ច និងការប្រែប្រួលអាកាសធាតុផងដែរ។ បន្ថែមពីនេះ ការវាយតម្លៃលើហេតុប៉ះពាល់ឆ្លងដែន ប្រើប្រាស់នូវសូចនាករគ្រប់ប្រភេទទាំងអស់ ទាំងសម្រាប់គ្រប់វិស័យ និងជំនាញខាងលើនេះ។

ជាទូទៅ ការសិក្សាក្រុមប្រឹក្សា និងការវាយតម្លៃកន្លងមកដែលរៀបចំដោយ MRC បានធ្វើឲ្យប្រទេសជាសមាជិក កាន់តែយល់ដឹងពីកាលានុវត្តភាព និងហានិភ័យផ្សេងៗនៃគម្រោងទំនប់វារីអគ្គិសនីលើដងទន្លេមេ។

ជាពិសេស សម្រាប់ដំណើរការ PNPCA ការសិក្សាក្រុមប្រឹក្សា ដើរតួនាទីយ៉ាងសំខាន់ ក្នុងនាមជាឧបករណ៍ ចំណេះដឹង ព័ត៌មាន ទិន្នន័យ និងការវាយតម្លៃ ដើម្បីគាំទ្រដល់រាល់កិច្ចការវាយតម្លៃហេតុប៉ះពាល់សម្រាប់ដំណើរការការពិគ្រោះយោបល់ជាមុននៃគម្រោងអភិវឌ្ឍន៍ពិតប្រាកដតាមដងទន្លេមេ។

## ២៣. តើការវាយតម្លៃផលប៉ះពាល់ឆ្លងដែន ជាលក្ខខណ្ឌតម្រូវមួយក្នុងដំណើរការការពិគ្រោះយោបល់ជាមុនឬ? តើមានការពិនិត្យ និងប្រើប្រាស់ព័ត៌មានស្តីពីផលប៉ះពាល់ឆ្លងដែនរបស់គម្រោងយ៉ាងដូចម្តេចខ្លះ?

បើតាម PNPCA ការវាយតម្លៃផលប៉ះពាល់ឆ្លងដែន ទាំងផ្នែកសង្គម និងសេដ្ឋកិច្ច ឬក៏ផ្នែកបរិស្ថាន មិនមែនជាលក្ខខណ្ឌតម្រូវនោះឡើយ ដោយសារពុំមានបញ្ញត្តិណាមួយ តម្រូវឱ្យប្រទេសជូនដំណឹងធ្វើការវាយតម្លៃបែបនេះឡើយ។ ប៉ុន្តែ វាមានសារៈសំខាន់ណាស់ ដែលប្រទេសជូនដំណឹងត្រូវផ្តល់នូវព័ត៌មានវាយតម្លៃទាំងនេះ ដើម្បីផ្តល់លទ្ធភាពដល់ប្រទេសដែលទទួលបានការជូនដំណឹង ក៏ដូចជាលេខាធិការដ្ឋាន MRC ធ្វើការវាយតម្លៃ និងពិភាក្សាពីវិធានការនានា ដើម្បីកាត់បន្ថយជា អប្បបរមា និងសម្រាលផលប៉ះពាល់ឆ្លងដែនដែលអាចកើតមាន។ ដោយមូលហេតុនេះ PDG ដែលធ្វើបានបច្ចុប្បន្នភាពថ្មី ក៏រួមបញ្ចូលនូវចំណុចខ្វះខាតទាំងនេះផងដែរ។

###